អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**

- គម្រោងវិនិយោគថ្មី ចំនួន២,៤ ប៊ីលានដុល្លារ សម្រាប់ពាក់កណ្ដាលឆ្នាំដំបូង
- សហគ្រាសចំនួន ១៨% នៅកម្ពុជាមានការលំបាកក្នុងការស្វែងរកកម្មករដែលមានជំនាញត្រឹមត្រូវ
- ច្បាប់ស្ដីពី ប្រព័ន្ធគាំពារសង្គម នឹងជួយកាត់បន្ថយភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច
- តារាងទី១៖ តារាងប្រៀបធៀបតម្លៃផលិតផលនាំចេញ ប្រចាំខែមេសា ឆ្នាំ២០២១
- តារាងទី២៖ តារាងប្រៀបធៀបទីផ្សារគោលដៅនាំចេញ ប្រចាំខែមេសា ឆ្នាំ២០២១
- ការប្រែប្រួលទៅលើអត្រានៃភាពគ្មានការងារធ្វើ របស់បណ្ដាប្រទេសក្នុងតំបន់អាស៊ាន
- ការប្រៀបធៀបពាណិជ្ជកម្មរបស់ថៃ សម្រាប់ត្រីមាសទី១ ឆ្នាំ២០២១ ទៅនឹងត្រីមាសទី១ ឆ្នាំ២០២០
- អតិរេកពាណិជ្ជកម្មរបស់ឥណ្ឌូណេស៊ី សម្រាប់ខែឧសភា ឆ្នាំ២០២១
- កំណើននៃវិស័យសេវាកម្មរបស់ចិន ធ្លាក់ចុះដល់កម្រិតទាបបំផុតក្នុងរយៈពេល១៤ខែក្នុងខែមិថុនា ឆ្នាំ២០២១
- វិបត្តិកង្វះបន្ទះឈីប កំពុងប៉ះពាល់ដល់វិស័យផលិតគ្រឿងអេឡិចត្រូនិចនៅប្រទេសជប៉ុន
- សកម្មភាពអាជីវកម្មនៅតំបន់អឺរ៉ុបបានកើនឡើងខ្ពស់វិញនៅក្នុងខែមិថុនា បន្ទាប់ពីការបិទខ្ទប់ត្រូវបានបញ្ចប់
- អាមេរិក និងតៃវ៉ាន់ បន្តកិច្ចពិភាក្សាជំនួញជាថ្មី ក្រោយផ្អាករយៈពេល៥ឆ្នាំ


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី — អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា — អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី — ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ — អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា



រៀបរៀងដោយនាយកដ្ឋានស្រាវជ្រាវថវិកា សប្ដាហ៍ទី២ ខែកក្កដា ឆ្នាំ២០២១ លេខ៖ ៧៥

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### គម្រោងវិនិយោគថ្មី ចំនួន២,៤ ប៊ីលានដុល្លារ សម្រាប់ពាក់កណ្តាលឆ្នាំដំបូង



*ប្រភព៖ Heng Chivoan, Phnom Penh Post ២០២១*

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) បានអនុម័តគម្រោងចំនួន៧០ ដែលមានទុនវិនិយោគសរុបចំនួន ២,៤២៨ ប៊ីលានដុល្លារនៅឆមាសទីមួយនៃឆ្នាំនេះ។ គម្រោងទាំងនោះ រួមមាន៖ គម្រោងវិនិយោគចំនួន ២៩ លើវិស័យវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរ ដែលមានទុនវិនិយោគចំនួន ១៩៤,៧១លានដុល្លារ, គម្រោងរោងចក្រគ្រឿងបន្លាស់អគ្គិសនី និងកង់ចំនួន១២ ដែលមានទុនវិនិយោគចំនួន១១៦,៥ លានដុល្លារ និងគម្រោងរោងចក្រគ្រឿងសង្ហារឹម ចំនួន៤ ដែលមានទុនវិនិយោគចំនួន ៥៥,៦ លានដុល្លារ។

ទន្ទឹមនឹងនេះ CDC បានអនុម័តគម្រោងធំៗ ចំនួន៣ ក្នុងវិស័យថាមពល រួមមានគម្រោងរោងចក្រថាមពលដើរដោយធ្យូងថ្ម ៧០០មេហ្គាវ៉ាត់ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ នៅស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ដោយមានទុនវិនិយោគ ១,២៨៣ប៊ីលានដុល្លារ និងគម្រោង២ទៀត គឺកសិដ្ឋានថាមពលពន្លឺព្រះអាទិត្យ ២០មេហ្គាវ៉ាត់ ដែលមានទឹកប្រាក់ ១៧,៦លានដុល្លារ នៅភូមិមនោរម្យ ឃុំស្វាយទិព្វ ស្រុកស្វាយទាប ខេត្តស្វាយរៀង និងរោងចក្រថាមពលពន្លឺព្រះអាទិត្យចំនួន ៧,៨ លានដុល្លារ នៅតំបន់សេដ្ឋកិច្ចពិសេសគីរីសាគរ ខេត្តកោះកុង ព្រមទាំងបានអនុម័តគម្រោងមួយចំនួនក្នុងវិស័យបដិសណ្ឋារកិច្ចរួមមាន៖ សណ្ឋាគារ លំដាប់ផ្កាយ ៥ ក៏ដូចជារោងចក្រកែច្នៃអាហារ និងរោងចក្រកែច្នៃកសិកម្មផងដែរ។

ដោយឡែកលោក លឹម ហេង អនុប្រធានសភាពាណិជ្ជកម្មកម្ពុជា បានកត់សម្គាល់ថា វិស័យវាយនភណ្ឌកាត់ដេរ សម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរ មានទំហំធំជាងគេសម្រាប់ការវិនិយោគដែលបានអនុម័តថ្មីៗ ដើម្បីនាំចេញទៅសហភាពអឺរ៉ុប បើទោះបីជាប្លុកនេះ បានដកផ្នែកខ្លះនៃគម្រោង(EBA)កាលពីឆ្នាំមុនក៏ដោយ។

ជាមួយគ្នានេះ ប្រព័ន្ធអនុគ្រោះពន្ធទូទៅរបស់ចក្រភពអង់គ្លេសនឹងជំរុញលំហូរចូលការវិនិយោគផ្ទាល់ពីបរទេស (FDI) មកកម្ពុជា ខណៈដែលយុទ្ធនាការចាក់វ៉ាក់សាំង ១០លាននាក់របស់រាជរដ្ឋាភិបាល នឹងរួមចំណែកដល់កំណើននៃការវិនិយោគនៅកម្ពុជាផងដែរ ពីព្រោះអ្នកវិនិយោគ នឹងមិនមានការបារម្ភ អំពីផលប៉ះពាល់លើសកម្មភាពអាជីវកម្មរបស់ពួកគេឡើយ។

*ដោយ វ៉ា វង្សវឌ្ឍនៈ*

*ប្រភព៖ Phnom Penh Post ចេញផ្សាយថ្ងៃទី០៥ ខែកក្កដា ឆ្នាំ ២០២១*

## សហគ្រាសចំនួន ១៨% នៅកម្ពុជាមានការលំបាកក្នុងការស្វែងរកកម្មករដែលមានជំនាញត្រឹមត្រូវ



*ប្រភព៖ Khmer Times ២០២១*

ការអភិវឌ្ឍធនធានមនុស្ស បានដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យសេដ្ឋកិច្ចរីកចម្រើន។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលជំនាញរបស់កម្មករ មិនស្របតាមតម្រូវការឧស្សាហកម្ម ភាពមិនស៊ីសង្វាក់ និងអតុល្យភាពនៅក្នុងទីផ្សារការងារ អាចរារាំងដល់សេដ្ឋកិច្ចមិនឱ្យឈានដល់សក្តានុពលរបស់ខ្លួន។ ជាមួយគ្នានេះដែរ ការរកឃើញតាមរយៈការស្ទង់មតិពីសហគ្រាសចុងក្រោយបង្អស់របស់ធនាគារពិភពលោក បង្ហាញថា ចន្លោះពី ១០% ទៅ ១៥% នៃនិយោជក នៅប្រទេសហ្វីលីពីន ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី និង ១៨% នៅកម្ពុជា មានការលំបាកក្នុងការស្វែងរកកម្មករ ដែលមានជំនាញត្រឹមត្រូវសម្រាប់ប្រតិបត្តិការរបស់ពួកគេ ហើយតិចជាង ៥% នៃក្រុមហ៊ុននៅក្នុងប្រទេសថៃ បានជួបប្រទះនូវគុណវិបត្តិនេះ។

ភាពមិនស៊ីចង្វាក់គ្នានៃជំនាញ មិនត្រឹមតែប៉ះពាល់ដល់បណ្ដាប្រទេសអ្នកមាន នៅក្នុងអង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) ប៉ុណ្ណោះទេ ថែមទាំងប៉ះពាល់ដល់ប្រទេសសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ រួមទាំងប្រទេសនៅអាស៊ីអាគ្នេយ៍ផងដែរ។ ការសិក្សានេះ ក៏បានបង្ហាញពីចំនួនកម្មករយ៉ាងច្រើន ដែលទទួលបានការបណ្តុះបណ្តាលមិនស៊ីសង្វាក់ នឹងតម្រូវការជាក់ស្តែងរបស់និយោជក។ ជាមួយគ្នានេះដែរ ដោយសារការរាតត្បាតកូវីដ-១៩ បានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ប្រតិបត្តិការអាជីវកម្ម តម្រូវការជំនាញ និងសេណារីយ៉ូការងារ បានផ្លាស់ប្តូរនៅក្នុងវិស័យជាច្រើន។ កម្មករជាច្រើនបានបាត់បង់ការងាររបស់ពួកគេជាបណ្តោះអាសន្ន ឬ ជាអចិន្ត្រៃយ៍ ហើយអ្នកខ្លះនឹងត្រូវផ្លាស់ការងារទៅវិស័យផ្សេងទៀត ប្រសិនបើពួកគេចង់នៅមានការងារធ្វើ ដែលតម្រូវឱ្យធ្វើការបង្កើនជំនាញ និងការប្តូរជំនាញឡើងវិញ។ ទោះយ៉ាងណា ជំងឺរាតត្បាតនេះ ក៏បានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើការពង្រឹងជំនាញ។ ការសិក្សា និងការធ្វើការងារ ត្រូវបានធ្វើឡើងតាមប្រព័ន្ធអនឡាញ ដូច្នេះ អ្នកដែលមានបរិយាកាសសិក្សានៅផ្ទះដែលមិនសូវអំណោយផល មានហានិភ័យខ្ពស់ក្នុងការតាមមិនទាន់។

ទន្ទឹមនឹងនេះ តាមរយៈអ្នកជំនាញ បានបង្ហាញថា ភាពមិនស៊ីសង្វាក់គ្នានៃការសិក្សា ក៏អាចជាបញ្ហាសម្រាប់មនុស្សផងដែរ ព្រោះពួកគេត្រូវបានបង្ខំឱ្យទទួលយកការងារកម្រិតទាបដោយសារតែកង្វះចំណេះដឹងជាក់លាក់។ ការមិនស៊ីសង្វាក់គ្នានៃជំនាញនេះគឺបង្ហាញនូវការបែងចែកធនធានគ្មានប្រសិទ្ធភាព ដែលនាំឱ្យមានឧបសគ្គរាំងដល់កំណើនសេដ្ឋកិច្ចបន្ថែមទៀត។

*ដោយ វត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ Khmer Times ចេញផ្សាយថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២១*

## ច្បាប់ស្តីអំពី ប្រព័ន្ធគាំពារសង្គម នឹងជួយកាត់បន្ថយភាពរងគ្រោះផ្នែកសេដ្ឋកិច្ច




*រូបថត FN*

រាជរដ្ឋាភិបាលកម្ពុជា កំពុងពិនិត្យសេចក្តីព្រាងច្បាប់ស្តីពី ប្រព័ន្ធគាំពារសង្គម។ សេចក្តីព្រាងច្បាប់នេះបង្កើតឡើង ក្នុងគោលបំណងដើម្បីធានាសុខុមាលភាព និងកាត់បន្ថយភាពរងគ្រោះផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពង្រឹងសន្តិសុខប្រាក់ចំណូលរបស់ប្រជាជន និងលើកកម្ពស់សមភាពសង្គមតាមរយៈការបង្កើត និងគ្រប់គ្រងប្រព័ន្ធគាំពារសង្គម ប្រកបដោយបរិយាប័ន្ន វឌ្ឍនភាព និងចីរភាពហិរញ្ញវត្ថុ។

ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម បានលើកឡើងថា រាជរដ្ឋាភិបាលទទួលស្គាល់ពីសារៈសំខាន់ នៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ក្នុងការធានាសុខុមាលភាពផ្នែកហិរញ្ញវត្ថុប្រជាពលរដ្ឋខ្មែរ។ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់នូវលទ្ធភាពក្នុងការទទួលបាននូវសេវានានា ដែលគ្របដណ្តប់ដោយកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈ និងវិស័យឯកជន។ ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពី ប្រព័ន្ធគាំពារសង្គម គឺស្របនឹងទស្សនៈវិស័យរបស់រាជរដ្ឋាភិបាល ក្នុងការប្រែក្លាយពីប្រទេសមានចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅក្នុងឆ្នាំ ២០៣០ និងប្រែក្លាយជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។ ដូច្នេះ ដើម្បីធានាបាននូវសន្តិសុខប្រាក់ចំណូលប្រជាពលរដ្ឋ រាជរដ្ឋាភិបាលត្រូវកំណត់ចក្ខុវិស័យវែងឆ្ងាយក្នុងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ដែលជាឧបករណ៍បម្រើដល់ការកាត់បន្ថយ និងទប់ស្កាត់ភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាពសង្គម។

លោក ហុង វណ្ណៈ អ្នកស្រាវជ្រាវរបស់វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជា បានឱ្យដឹងថា បើច្បាប់នេះត្រូវបានបង្កើតឡើង វានឹងមានអត្ថប្រយោជន៍យ៉ាងសំខាន់ទៅលើការការពារហានិភ័យដែលកើតឡើងដោយថាហេតុ ដូចជាជំងឺ ឬរោគរាតត្បាតកាចសាហាវ និងប្រធានស័ក្តិមួយចំនួន។ កិច្ចការនេះ គឺផ្តោតលើការចំណាយថវិការដ្ឋសម្រាប់សង្គ្រោះទៅលើហានិភ័យដែលអាចកើតមានដោយថាហេតុ និងដើម្បីជួយសង្គ្រោះបន្ទាន់ដល់ជនងាយរងគ្រោះ ក៏ដូចជាក្រុមហ៊ុន សហគ្រាសធុនតូច និងមធ្យម។

ជាក់ស្តែង ដោយស្ថានភាពជំងឺកូវីដ-១៩នៃព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ នៅតែបន្តវិវឌ្ឍន៍ខ្លួនគួរឱ្យបារម្ភ រាជរដ្ឋាភិបាល បានសម្រេចដាក់ចេញនូវវិធានការជុំទី៩ ដើម្បីជួយរក្សាលំនឹងអាជីវកម្មក្នុងវិស័យមួយចំនួន។

រដ្ឋាភិបាលនឹងបន្តផ្តល់ប្រាក់ឧបត្ថម្ភ ៤០ដុល្លារ ក្នុង០១ខែ និងម្ចាស់រោងចក្រ សហគ្រាសបន្ថែម ៣០ ដុល្លារទៀត សម្រាប់កម្មករនិយោជិត ០១នាក់នៅក្នុងវិស័យកាត់ដេរ ស្បែកជើង ផលិតផលធ្វើដំណើរ កាបូប។ ចំពោះនិយោជិតវិស័យទេសចរណ៍ រដ្ឋបន្តឧបត្ថម្ភ ៤០ ដុល្លារក្នុង ០១ ខែ។

ជាមួយគ្នានេះ រដ្ឋក៏មានកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះផងដែរ ខណៈការផ្តល់ប្រាក់ឧបត្ថម្ភនេះត្រូវបានបន្តអនុវត្តក្នុងរយៈពេល ៣ខែទៀត គឺចាប់ពីខែកក្កដា ដល់កញ្ញា ឆ្នាំ ២០២១៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភពៈភ្នំពេញប៉ុស្ដិ៍ ចេញផ្សាយថ្ងៃទី៥ខែកក្កដាឆ្នាំ២០២១*

## តារាងប្រចាំសប្តាហ៍ ៖

## តារាងទី១៖ តារាងប្រៀបធៀបតម្លៃផលិតផលនាំចេញប្រចាំខែមេសា ឆ្នាំ២០២១

| ល.រ | ប្រភេទផលិតផល | ខែកុម្ភៈ ឆ្នាំ ២០២១(រៀល) | ខែមេសា ឆ្នាំ ២០២១(រៀល) | កំណើន (%) |
|---|---|---|---|---|
| | សរុបរួម | 1,132,880,174.72 | 2,008,221,567.31 | 77.27% |
| 1 | សំលៀកបំពាក់ | 540,389,522.43 | 349,313,803.58 | -35.36% |
| 2 | ស្បែកជើង | 94,833,921.48 | 69,622,089.72 | -26.59% |
| ៣ | វាយនភ័ណ្ឌ | 11,258,785.68 | 4,325,240.40 | -61.58% |
| 4 | អង្ករ | 48,248,922.88 | 92,619,463.17 | 91.96% |
| 5 | ការបូបធ្វើដំណើរ | 77,302,141.07 | 78,188,702.40 | 1.15% |
| 6 | ផលិតផលកសិកម្ម | 0.00 | 0.00 | គ្មាន |
| 7 | កង់ | 0.00 | 0.00 | គ្មាន |
| 8 | ផលិតផលផ្សេងៗ | 360,846,881.18 | 1,414,152,268.04 | 291.90% |

**បញ្ជាក់៖ ទិន្នន័យនេះមិនរាប់បញ្ចូលតំបន់សេដ្ឋកិច្ចពិសេសទេ។**

*ប្រភព៖ ក្រសួងពាណិជ្ជកម្មកម្ពុជា ចុះនាថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០២១*

តារាងទី១ ខាងលើនេះបង្ហាញ ពីការប្រៀបធៀបការនាំចេញផលិតផលគ្រប់ប្រភេទក្នុងខែមេសា ឆ្នាំ២០២១ ដែលមានកំណើន ៧៧% បើធៀបនឹងខែកុម្ភៈក្នុងឆ្នាំដូចគ្នានេះ។ ផលិតផលនាំចេញទាំងនោះ រួមមាន ៖ សំលៀកបំពាក់ វាយនភ័ណ្ឌ អង្ករ ស្បែកជើង កង់ ផលិតផលកសិកម្ម កាបូបធ្វើដំណើរ និងផលិតផលផ្សេងៗ នេះបើយោងតាមព្រឹត្តិបត្រពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ដែលបានចេញផ្សាយនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ ២០២១។

ការនាំចេញផលិតផលនៅខែមេសា ឆ្នាំ២០២១នេះ មានការកើនឡើងខ្លាំងលើផលិតផលផ្សេងៗ និងអង្ករ។ ផលិតផលផ្សេងៗ មានការកើនឡើងយ៉ាងខ្លាំងជិត ២៩២% បន្ទាប់មកអង្ករ កើនជិត ៩២%។ រីឯការនាំចេញសំលៀកបំពាក់ ស្បែកជើង និងវាយនភ័ណ្ឌ បានថយចុះ៣៥%, ២៧%, និង៦២% រៀងគ្នា បើធៀបទៅនឹងខែកុម្ភៈក្នុងឆ្នាំដូចគ្នានេះ។ ចំពោះ កង់ និងផលិតផលកសិកម្មពុំមានសកម្មភាពទេ។ *ដោយ ឈន ហាំ*

## តារាងទី២៖ តារាងប្រៀបធៀបទីផ្សារគោលដៅ នាំចេញប្រចាំខែមេសា ឆ្នាំ២០២១

| ល.រ | ទីផ្សារគោលដៅ | ខែកុម្ភៈ ឆ្នាំ ២០២០(រៀល) | ខែមេសា ឆ្នាំ ២០២១ (រៀល) | កំណើន(%) |
|---|---|---|---|---|
| | សរុបរួម | 1,132,880,174.72 | 2,008,221,567.31 | 77.27% |
| 1 | សហរដ្ឋអាមេរិក | 321,577,030.72 | 226,302,906.77 | -29.63% |
| 2 | កាណាដា | 69,111,889.03 | 50,102,008.78 | -27.51% |
| ៣ | ជប៉ុន | 64,385,851.28 | 60,921,744.64 | -5.38% |
| 4 | សហគមអ៊ឺរ៉ុប | 151,792,963.76 | 88,538,003.30 | -41.67% |
| 5 | អាស៊ាន | 314,633,618.22 | 1,358,580,397.53 | 331.80% |
| 6 | ចិន | 81,372,729.22 | 107,323,175.13 | 31.89% |
| 7 | កូរ៉េ | 16,138,175.27 | 13,838,933.43 | -14.25% |
| 8 | ប្រទេសដ៏ទៃទៀត | 113,867,917.22 | 102,614,397.73 | -9.88% |

**បញ្ជាក់៖ ទិន្នន័យនេះមិនរាប់បញ្ចូលតំបន់សេដ្ឋកិច្ចពិសេសទេ។**

*ប្រភព៖ ក្រសួងពាណិជ្ជកម្មកម្ពុជា ចុះនាថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០២១*

តារាងទី២ ខាងលើនេះ បង្ហាញ ពីការប្រៀបធៀបទីផ្សារគោលដៅ ឬ ប្រទេសគោលដៅ ក្នុងការនាំចេញផលិតផលគ្រប់ប្រភេទក្នុងខែមេសា ឆ្នាំ២០២១ ដែលមានកំណើន ៧៧% បើធៀបនឹងខែកុម្ភៈក្នុងឆ្នាំដូចគ្នា។ ផលិតផលទាំងនោះរួមមាន៖ សំលៀកបំពាក់ វាយនភ័ណ្ឌ អង្ករ ស្បែកជើង កង់ ផលិតផលកសិកម្ម កាបូបធ្វើដំណើរ

និងផលិតផលផ្សេងៗ។ ផលិតផលទាំងនោះត្រូវបាននាំចេញទៅប្រទេសគោលដៅជាច្រើនដូចជា៖ សហរដ្ឋអាមេរិក កាណាដា ជប៉ុន សហគមន៍អ៊ឺរ៉ុប អាស៊ាន ចិន កូរ៉េខាងត្បូង និងប្រទេសដ៏ទៃទៀត នេះបើយោងតាមព្រឹត្តិបត្រពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ដែលបានចេញផ្សាយនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២១។

ការនាំចេញទំនិញខាងលើនេះ ទៅកាន់ប្រទេសក្នុងអាស៊ានមានការកើនឡើងយ៉ាងខ្លាំងជិត ៣៣២% និងទៅកាន់ប្រទេសចិនមានការកើន ៣២%។ ប៉ុន្តែ ការនាំចេញទៅកាន់ ប្រទេសជប៉ុន កូរ៉េខាងត្បូង កាណាដា សហរដ្ឋអាមេរិក សហគមអ៊ឺរ៉ុប និងប្រទេសដ៏ទៃទៀត គឺថយចុះ ៥%, , ១៤% , ២៨%, ៣០% , ៤២%, និង ១០% រៀងគ្នាបើធៀបនឹងខែកុម្ភៈក្នុងកំឡុងពេលដូចគ្នា។ *ដោយ ឈន ហាំ*

## ព័ត៌មាន និងទិន្នន័យរបស់បណ្ដាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ការប្រែប្រួលទៅលើអត្រានៃភាពគ្មានការងារធ្វើ របស់បណ្ដាប្រទេសក្នុងតំបន់អាស៊ាន

ស្របពេលដែលជំងឺកូវីដ-១៩ បានរីករាលដាលសារជាថ្មីនាពេលបច្ចុប្បន្ននេះ បណ្ដាប្រទេសនានានៅលើសកលលោកត្រូវជួបប្រទះនូវវិបត្តិសុខភាពផង និងការខាតបង់លើផ្នែកសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរផង ជាពិសេសការបង្អាក់នូវខ្សែសង្វាក់ផ្គត់ផ្គង់ និង ការផលិត ជាហេតុនាំឱ្យទីផ្សារការងារមានភាពផុយស្រួយ តាមរយៈការបញ្ឈប់ការងារបុគ្គលិក ឬព្យួរការងារបុគ្គលិក។

គេហទំព័រ world population review បានធ្វើចំណាត់ថ្នាក់នៃអត្រាភាពគ្មានការងារធ្វើ នៃបណ្ដាប្រទេសក្នុងអាស៊ាន (រូបភាពខាងក្រោម) និងបានបង្ហាញថា ក្នុងរយៈពេលបីឆ្នាំចុងក្រោយ ប្រទេសកម្ពុជា ជាប្រទេសមួយដែលមានអត្រាអ្នកគ្មានការងារធ្វើទាបជាងគេ គឺ ០,១% នៅឆ្នាំ២០១៩ និងអត្រា ០,៣%ថេរ នៅរយៈពេលពីរឆ្នាំបន្ទាប់ បើទោះបីជា ស្ថិតក្នុងបរិបទដែលទទួលរងផលប៉ះពាល់ខ្លាំងពីជំងឺកូវីដ-១៩ក៏ដោយ ក៏កម្ពុជានៅតែរក្សាបានអត្រាទាបជាងគេដដែល ក្នុងតំបន់អាស៊ីអាគ្នេយ៍។ លទ្ធផលនេះអាចសម្រេចបានដោយសារការចាត់វិធានការណ៍កញ្ចប់ថវិកាជំនួយសង្គមជាបន្តបន្ទាប់របស់រាជរដ្ឋាភិបាលកម្ពុជា ការគាំទ្រលើវិស័យអាទិភាព សម្រាប់ការវិនិយោគក្នុងស្រុក ព្រមទាំងយុទ្ធនាការក្នុងការផ្ដល់វ៉ាក់សាំងជូនកម្មករជាដើម។

ដោយឡែក ប្រទេសប្រ៊ុយណេវិញគឺជាប្រទេសមួយដែលមានអត្រាភាពអត់ការងារធ្វើខ្ពស់ជាងគេ នៅ ក្នុងតំបន់អាស៊ាន ដែលមានអត្រា ៦,៩% នៅក្នុងឆ្នាំ២០១៩ និងបន្តកើនឡើងរហូតដល់អត្រាជិត ៨,៤% នៅក្នុងឆ្នាំ២០២០។ ការកើនឡើងនេះ បណ្ដាលមកពីអាជីវកម្មមួយចំនួនធំ ត្រូវផ្លាស់ប្ដូរប្រតិបត្តិការអាជីវកម្មរបស់ខ្លួន ហើយ អាជីវកម្មខ្លះ ត្រូវបានបិទជាបណ្ដោះអាសន្ន រួមទាំងការហាមឃាត់រាល់ការធ្វើដំណើរក្នុងនិងក្រៅប្រទេស។ ការណ៍នេះបានបណ្ដាលឱ្យ អ្នកធ្វើការមួយចំនួនធំ ត្រូវស្នើសុំឱ្យឈប់សម្រាកពីការងារ។ ទោះយ៉ាងណា អត្រានេះបានធ្លាក់ចុះមកវិញត្រឹម ៦,៩%នៅក្នុងឆ្នាំ២០២១នេះ។

ចំណែកឯ ប្រទេសមីយ៉ាន់ម៉ាវិញ អត្រានៃភាពគ្មានការងារកើនឡើងយ៉ាងខ្លាំងដល់៤% នៅឆ្នាំ២០២១ បើធៀបនឹងឆ្នាំ២០១៩ ដែលមានត្រឹមតែ ០,៥% ដែលការកើនឡើងនេះបណ្ដាលមកពីកត្តាសន្តិសុខក្នុងប្រទេសជាហេតុនាំឱ្យក្រុមហ៊ុនមួយចំនួនធំចាំបាច់ត្រូវផ្លាស់ប្ដូរ

ទីតាំងទៅកាន់បណ្តាប្រទេសផ្សេងទៀត ទើបធ្វើឱ្យកម្មករមួយចំនួនធំត្រូវបាត់បង់ការងារ ស្របពេលកំពុងជួបវិបត្តិនៃការរាតត្បាតនៃវីរុសកូវីដ-១៩ ដូចប្រទេសផ្សេងទៀតដែរ។ *ដោយ សេន ចន្ធី*

រូបភាព៖ អត្រាភាពគ្មានការងារធ្វើ ធៀបនឹងចំនួនអ្នកអាចធ្វើការបាន (គិតជាភាគរយ, %)




*ប្រភព៖ Worldpopulationreview.បោះពុម្ពផ្សាយ ឆ្នាំ២០២១*

## ការប្រៀបធៀបពាណិជ្ជកម្មរបស់ថៃ សម្រាប់ត្រីមាសទី១ ឆ្នាំ២០២១ ទៅនឹងត្រីមាសទី១ ឆ្នាំ២០២០

ក្រាហ្វិចខាងក្រោមបង្ហាញពីការប្រៀបធៀបពាណិជ្ជកម្មរបស់ប្រទេសថៃ សម្រាប់ត្រីមាសទី១ ឆ្នាំ២០២១ ជាមួយនឹងត្រីមាសទី១ ឆ្នាំ២០២០។

សម្រាប់បីខែដំបូង នៃឆ្នាំ២០២១ ការផ្លាស់ប្តូរពាណិជ្ជកម្មមានតិចតួច បើទោះបីជាការនាំចេញនៅក្នុង ខែមីនាមានភាពល្អប្រសើរក៏ដោយ។ ទំហំពាណិជ្ជកម្មសរុបបានកើនឡើង ៥,៧% រហូតដល់ ១២៧,៨ ពាន់លានដុល្លារអាមេរិក បើធៀបនឹងត្រីមាសទី១ ឆ្នាំ២០២០។ ការនាំចេញបានកើនឡើង ២,៣% រហូតដល់ ៦៤,១ ពាន់លានដុល្លារអាមេរិក ខណៈដែលទំហំនាំចូលបានកើនឡើង ៩,៤% រហូតដល់ ៦៣,៦ ពាន់លានដុល្លារអាមេរិក។

ចំណែកឯ តុល្យភាពពាណិជ្ជកម្មមានអតិរេកចំនួន ៥១៦ លានដុល្លារសហរដ្ឋអាមេរិក នៅក្នុងត្រីមាសទី១ នៃឆ្នាំនេះ ខណៈដែលតុល្យភាពពាណិជ្ជកម្មនៅក្នុងត្រីមាសទី១ នៃឆ្នាំ២០២០ មានរហូតដល់ ៤,៥ ពាន់លានដុល្លារអាមេរិក។ ការថយចុះនៃតុល្យភាពពាណិជ្ជកម្មនេះ ដោយសារតែការនាំចេញទៅកាន់ប្រទេសស្វីសបានធ្លាក់ចុះពី ២,០៥ ពាន់លានដុល្លារអាមេរិក ក្នុងរយៈពេលបីខែដំបូងនៃឆ្នាំ២០២០ មកនៅត្រឹម ១៧៩ លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០២១ ហើយទំហំនៃការនាំចូលពីប្រទេសស្វីសបានកើនឡើងពី ៥២០ លានដុល្លារអាមេរិក ក្នុងរយៈពេលបីខែដំបូង នៃឆ្នាំ២០២០ ដល់ ២,៤៤ ពាន់លានដុល្លារអាមេរិកនៅត្រីមាសទី១ នៃឆ្នាំ២០២១។*ដោយ ជឹម ប៊ុនធឿន*




*ប្រភព៖ https://www.thaiwebsites.com*

## អតិរេកពាណិជ្ជកម្មរបស់ឥណ្ឌូណេស៊ី សម្រាប់ខែឧសភា ឆ្នាំ២០២១

យោងតាម ក្រសួងហិរញ្ញវត្ថុរបស់ប្រទេសឥណ្ឌូណេស៊ី-ស្ថិតិឥណ្ឌូណេស៊ី (BPS) ការនាំចេញរបស់ឥណ្ឌូណេស៊ី នៅក្នុងខែឧសភា ឆ្នាំ២០២១ ឈានដល់ ១៦,៦០ ពាន់លានដុល្លារអាមេរិក។ ទន្ទឹមនឹងនេះដែរ ការនាំចូលរបស់ឥណ្ឌូនេស៊ីទាំងមូលនៅក្នុងខែឧសភា ឆ្នាំ២០២១ មានចំនួន ១៤,២៣ ពាន់លានដុល្លារអាមេរិក។ នេះបង្ហាញថា តុល្យភាពពាណិជ្ជកម្មរបស់ឥណ្ឌូណេស៊ីក្នុងខែឧសភា ឆ្នាំ២០២១ មានអតិរេកចំនួន ២,៣៧ ពាន់លានដុល្លារ។

ព័ត៌មានលម្អិតបន្ថែមទៀត ការនាំចេញមិនមែនប្រេង និងឧស្ម័ន (non-oil and gas exports) នៅក្នុងខែឧសភា ឆ្នាំ២០២១ បានឈានដល់ ១៥,៦៦ ពាន់លានដុល្លារ ពោលគឺថយចុះ ១០,៦៧% បើប្រៀបធៀបទៅនឹងខែមេសា ឆ្នាំ២០២១។

គួរបញ្ជាក់ផងដែរថា ការនាំចេញរបស់ឥណ្ឌូណេស៊ីពីខែមករា ដល់ខែឧសភា ឆ្នាំ២០២១ មានចំនួន ៨៣,៩៩ពាន់លានដុល្លារអាមេរិក កើនឡើង ៣០,៥៨% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០៕

*ដោយ ធីម ប៊ុនធឿន*

| | មេសា ឆ្នាំ ២០២១ | ឧសភា ឆ្នាំ ២០២១ |
|---|---|---|
| ការនាំចេញ | 18.49 | 16.60 |
| ការនាំចូល | 16.20 | 14.23 |
| តុល្យភាពពាណិជ្ជកម្ម | 2.29 | 2.37 |

*ប្រភព៖ Central Bureau of Statistics (bps.go.id)*

## សិង្ហបុរី នឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ជាមួយសម្ព័ន្ធមិត្តប៉ាស៊ីហ្វិក នៅត្រឹមដំណាច់ឆ្នាំ២០២១



*ប្រភព ៖ AKP*

នៅត្រឹមដំណាច់ឆ្នាំនេះ ប្រទេសសិង្ហបុរីនឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) ជាមួយសម្ព័ន្ធមិត្តប៉ាស៊ីហ្វិក(PA) ដែលជាប្លុកពាណិជ្ជកម្ម មានប្រទេសចំនួន៤ នៅតំបន់អាមេរិកឡាទីន រួមមានប្រទេសឈីលី កូឡុំប៊ី ម៉ិកស៊ិក និងប៉េរូ។

កិច្ចព្រមព្រៀងនេះ នឹងធ្វើឱ្យក្រុមហ៊ុនអាជីវកម្មទាំងសងខាងអាចទទួលបានឱកាសទីផ្សារ និងជំរុញកិច្ចសហប្រតិបត្តិការកាន់តែខ្លាំង នៅក្នុងវិស័យមួយចំនួនដូចជា វិស័យពាណិជ្ជកម្ម អេឡិចត្រូនិច គយ ការសម្របសម្រួលពាណិជ្ជកម្ម និងសេវាកម្មសមុទ្រ។

ក្នុងឆ្នាំ ២០១៩ តម្លៃពាណិជ្ជកម្មរបស់ប្រទេសសិង្ហបុរីជាមួយ PA បានកើនដល់ ៦,១ប៊ីលានដុល្លារសិង្ហបុរី (៤,៥ប៊ីលានដុល្លារអាម៉េរិក) ដែលស្មើនឹង ៣៣,២% នៃពាណិជ្ជកម្មទំនិញសរុបរបស់សិង្ហបុរី ជាមួយបណ្តាប្រទេសក្នុងតំបន់អាមេរិកឡាទីន។ ទន្ទឹមនឹងនេះដែរ ចំណូលពីពាណិជ្ជកម្មសេវាកម្មជាមួយ PA នៅក្នុងឆ្នាំ ២០១៨បានឈានដល់តម្លៃ២,៦ប៊ីលានដុល្លារអាម៉េរិក

ស្មើនឹង ២៨,២ភាគរយនៃពាណិជ្ជកម្មសេវាកម្មសរុបរបស់សិង្ហបុរីជាមួយតំបន់នេះ។

ប្រទេសសិង្ហបុរី មានកិច្ចព្រមព្រៀងដែលមានស្រាប់រួចហើយជាមួយប្រទេសចំនួន ៣ នៃចំណោមប្រទេសទាំង ៤ នេះ ដែលមានប្រទេសឈីលី ម៉ិចស៊ិកូ និងប៉េរូ ដែលជារដ្ឋសមាជិក នៃកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយ និងជឿនលឿន សម្រាប់ភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (CPTPP)៕ *ដោយ ម៉ែន ខែមរៈ*

## សេដ្ឋកិច្ចសកល

### កំណើននៃវិស័យសេវាកម្មរបស់ចិន ធ្លាក់ចុះដល់កម្រិតទាបបំផុតក្នុងរយៈពេល១៤ខែក្នុងខែមិថុនាឆ្នាំ២០២១



*ប្រភព៖ Reuters ២០២១, រូបភាព៖ Reuters/Tingshu Wang*

កំណើននៃវិស័យសេវាកម្មរបស់ចិន បានធ្លាក់ចុះយ៉ាងខ្លាំងដល់កម្រិតទាបបំផុតក្នុងរយៈពេល ១៤ខែ នៅក្នុងខែមិថុនា ឆ្នាំ២០២១ ដោយសារការលេចចេញនូវករណីឆ្លងនៃជំងឺកូវីដ-១៩ បំលែងថ្មី នៅភាគខាងត្បូងនៃប្រទេសចិន ដែលបានបន្ថែមការព្រួយបារម្ភដល់ប្រទេសសេដ្ឋកិច្ចធំបំផុតលំដាប់ទី២ របស់ពិភពលោកមួយនេះ ក្នុងការបាត់បង់សន្ទុះខ្លះៗរបស់ខ្លួន នេះបើយោងតាមរបាយការណ៍ស្ទង់មតិឯកជន ដែលទើបតែចេញផ្សាយកាលពីថ្ងៃចន្ទ សប្តាហ៍នេះ។

សន្ទស្សន៍អ្នកគ្រប់គ្រងការបញ្ជាទិញខាងសេវាកម្មរបស់ប្រទេសចិន Caixin/Markit services Purchasing Managers' Index (PMI) បានធ្លាក់ចុះដល់ ៥០,៣ ក្នុងខែមិថុនា ឆ្នាំ២០២១ ដែលជាកម្រិតទាបបំផុតចាប់ពីខែមេសាឆ្នាំ២០២០ និងធ្លាក់ចុះយ៉ាងខ្លាំងពី ៥៥,១ ក្នុងខែឧសភា ឆ្នាំ២០២១។ តួលេខនេះ គឺនៅលើពិន្ទុ ៥០ បន្តិចប៉ុណ្ណោះ ដែលជាកម្រិតគោលប្រៀបធៀបរវាងការកើនឡើង និងការធ្លាក់ចុះនៃមូលដ្ឋានប្រចាំខែ។

ជាមួយគ្នានេះ គួបផ្សំនឹងការថយចុះនៅក្នុងវិស័យផលិត អ្នកវិភាគបាននិយាយថាលទ្ធផលនៃការស្ទង់មតិសន្ទស្សន៍ PMI បានបង្ហាញថាតម្រូវការអំឡុងពេលការរាតត្បាតនៃជំងឺកូវីដ-១៩ អាចនឹងបង្កើនឱ្យដល់កម្រិតខ្ពស់បំផុត ខណៈ ការងើបឡើងវិញនៃសេដ្ឋកិច្ចដ៏រឹងមាំរបស់ចិនពីវិបត្តិកូវីដ-១៩ គឺកំពុងចាប់ផ្តើមនៅកម្រិតមធ្យម។

ជារួម លទ្ធផលនៃការស្ទង់មតិបានបង្ហាញថា សន្ទស្សន៍ PMI ក្នុងខែមិថុនា ឆ្នាំ២០២១ រួមបញ្ចូលទាំងសន្ទស្សន៍សកម្មភាពផលិត និងសេវាកម្ម បានធ្លាក់ចុះដល់កម្រិតទាបបំផុតក្នុងរយៈពេល ១៤ខែ មកត្រឹម ៥០,៦ ពី ៥៣,៨ ក្នុងខែឧសភា ឆ្នាំ២០២១។

ទោះជាយ៉ាងណា បើយោងតាមសម្តីរបស់លោក Wang Zhe សេដ្ឋវិទូជាន់ខ្ពស់ប្រចាំក្រុមហ៊ុន Caixin

Insight Group «ឧស្សាហកម្មផលិត បានវិលត្រឡប់មករកភាពប្រក្រតីវិញហើយ បន្ទាប់ពីការផ្ទុះឡើងនៃជំងឺរាតត្បាតកូវីដ-១៩ ខណៈដែលវិស័យសេវាកម្ម នៅតែប្រឈម ដោយសារតែករណីឆ្លងថ្មីនៅក្នុងតំបន់»។ បន្ថែមពីនេះ ឥទ្ធិពលកម្រិតទាបនៃសន្ទស្សន៍ PMI កាលពីឆ្នាំមុន នឹងបន្តធ្វើឱ្យធ្លាក់ចុះនូវសន្ទស្សន៍ PMI នៅពាក់កណ្តាល នៃឆ្នាំ២០២១ នេះ ខណៈ សម្ពាធអតិផរណានៅតែជាបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរចំពោះការធ្លាក់ចុះនៃសេដ្ឋកិច្ច។

សូមបញ្ជាក់ដែរថា ការផ្ទុះឡើងនូវការរីករាលដាលកាន់តែច្រើននៃជំងឺកូវីដ-១៩ បំលែងថ្មី Delta បានធ្វើឱ្យប៉ះពាល់ដល់មជ្ឈមណ្ឌលនាំចេញ និងផលិតកម្មនៅក្នុងខេត្ត Guangdon ចាប់តាំងពីចុងខែឧសភា ឆ្នាំ២០២១។ ការឆ្លើយតបយ៉ាងឆាប់រហ័សរបស់រដ្ឋាភិបាលតាមរយៈការដាក់ចេញនូវវិធានការបន្តបន្ទាប់ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ បានធ្វើឱ្យប៉ះពាល់ដល់អ្នកប្រើប្រាស់ និងសកម្មភាពអាជីវកម្ម៕

*ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ គេហទំព័រសារព័ត៌មាន Reuters ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១*

## វិបត្តិកង្វះបន្ទះឈីប កំពុងប៉ះពាល់ដល់វិស័យផលិតគ្រឿងអេឡិចត្រូនិចនៅប្រទេសជប៉ុន




*ប្រភព៖ The Japan Times ២០២១*

ការអូសបន្លាយពេល នៃវិបត្តិកង្វះវត្ថុធាតុដើមឧបករណ៍អគ្គិសនី (semiconductors) នៅទូទាំងពិភពលោក កំពុងចាប់ផ្តើមផ្តល់ផលប៉ះពាល់ដល់ក្រុមហ៊ុនផលិតសម្ភារៈប្រើប្រាស់ក្នុងផ្ទះ និងគ្រឿងអេឡិចត្រូនិចនៅក្នុងប្រទេសជប៉ុន។ ជាក់ស្តែង កង្វះវត្ថុធាតុដើមឧបករណ៍អគ្គិសនី បានបណ្តាលឱ្យមានការពន្យារពេលក្នុងការចែកចាយរថយន្ត។

ហាងលក់គ្រឿងបន្លាស់ សម្រាប់រថយន្តជាច្រើននៅក្នុងទីក្រុងតូក្យូ បានអស់ពីស្តុក នូវឧបករណ៍ប្រព័ន្ធសំឡេង និងប្រព័ន្ធប្រាប់ទិសរថយន្ត។ យោងតាមក្រុមហ៊ុនផលិតឧបករណ៍ប្រព័ន្ធសម្លេង និងប្រព័ន្ធប្រាប់ទិសឈ្មោះថា JVCKenwood Corp. ជាមួយក្តីរំពឹងនៃផលប៉ះពាល់កង្វះបន្ទះឈីបរហូតពេញមួយរដូវក្តៅក្នុងឆ្នាំ២០២១ នេះ ក្រុមហ៊ុនគ្រោងនឹងដោះស្រាយផ្នែកខ្លះនៃបញ្ហាតាមរយៈការផ្លាស់ប្តូរលក្ខណៈពិសេសនៃផលិតផលរបស់ខ្លួន។ ចំណែកឯ ក្រុមហ៊ុនផលិតហ្គេមដ៏ធំមួយឈ្មោះថា Nintendo បានកំណត់ទិសដៅលក់នៃឆ្នាំ២០២១ របស់ខ្លួន សម្រាប់វីដេអូហ្គេមឈ្មោះថា Nintendo Switch

ចំនួន ២៥,៥លានគ្រឿងប៉ុណ្ណោះ ពេលគឺធ្លាក់ចុះប្រមាណ ១០% ពីការលក់ដែលសម្រេចបានក្នុងឆ្នាំកន្លងមក ដោយសារភាពមិនប្រាកដប្រជាកំពុងកើនឡើងជុំវិញផែនការផលិតកម្មរបស់ក្រុមហ៊ុន នេះបើយោងតាមសម្តីរបស់លោក Shuntaro Furukawa ប្រធានក្រុមហ៊ុន Nintendo។

ទន្ទឹមនឹងនេះដែរ ក្រុមហ៊ុន Fujitsu General Ltd. ក៏កំពុងប្រឈមនឹងការលំបាកក្នុងការផ្គត់ផ្គង់គ្រឿងបន្លាស់ម៉ាស៊ីនត្រជាក់ដែរ ដោយសារគ្រោះអគ្គីភ័យកាលពីខែមីនា ឆ្នាំ២០២១ នៅឯក្រុមហ៊ុនផលិតបន្ទះឈីបដ៏ធំ និងល្បីល្បាញឈ្មោះថា Renesas Electronics Corp. ដែលមានទីតាំងនៅក្នុងខេត្ត Ibaraki បានជះឥទ្ធិពលដល់ការផលិតម៉ាស៊ីនត្រជាក់របស់ក្រុមហ៊ុន។

ទោះយ៉ាងនេះក្តី យោងតាមសមាគមឧស្សាហកម្មផលិតឧបករណ៍ និងសម្ភារៈវត្ថុធាតុដើមឧបករណ៍អគ្គិសនីអន្តរជាតិ (Semiconductor Equipment and Materials International) ក្រុមហ៊ុនផលិតបន្ទះឈីបនៅជុំវិញពិភពលោកគ្រោងនឹងចាប់ផ្តើមសាងសង់រោងចក្រថ្មីសរុបចំនួន ២៩ នៅត្រឹមឆ្នាំ២០២២។ ប៉ុន្តែរោងចក្រទាំងនោះ ត្រូវបានរំពឹងថានឹងមានដំណើរការក្នុងរយៈពេល ២ឆ្នាំ ឬច្រើនជាងនេះ បន្ទាប់ពីចាប់ផ្តើមសាងសង់។ *ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ [គេហទំព័រសារព័ត៌មាន The Japan TImes]() ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១*

## សកម្មភាពអាជីវកម្មនៅតំបន់អឺរ៉ុបបានកើនឡើងខ្ពស់ក្នុងខែមិថុនា បន្ទាប់ពីការបិទខ្ទប់ត្រូវបានបញ្ចប់



*ប្រភព៖ reuters, 2021 រូបភាព៖ Sarah Meyssonnier*

តាមរយៈការស្ទង់មតិរបស់សារព័ត៌មាន Reuters បានបង្ហាញថា អាជីវកម្មនៅតំបន់អឺរ៉ុបបានពង្រីកសកម្មភាពក្នុងអត្រាលឿនបំផុតនៅក្នុងខែមិថុនា ដែលពុំធ្លាប់មានក្នុងរយៈពេល១៥ឆ្នាំកន្លងមក ហើយការកើនឡើងនេះគឺដោយសារ ការបន្ធូរបន្ថយការរឹតបន្តឹង លើការឆ្លងនៃជំងឺកូវីដ-១៩ ទើបធ្វើឱ្យរាល់សកម្មភាព ឧស្សាហកម្ម និងសេវាកម្ម មានភាពប្រសើរឡើងវិញ។ ប៉ុន្តែ ការកើនឡើងនៃកំណើនសកម្មភាពទាំងនេះបានធ្វើឱ្យមានសម្ពាធអតិផរណា តាមរយៈកង្វះកម្លាំងពលកម្ម និងផលរំខានដល់ខ្សែសង្វាក់ផ្គត់ផ្គង់ ដែលបណ្តាលមកពីជំងឺរាតត្បាតកូវីដ-១៩។

យោងតាមរបាយការណ៍ចុងក្រោយនៃ សន្ទស្សន៍អ្នកគ្រប់គ្រងការទិញ (PMI) បានបង្ហាញថា រង្វាស់នៃសុខភាពសេដ្ឋកិច្ចបានកើនឡើងដល់ ៥៩,៥ នៅក្នុងខែមិថុនា ដែលកើនពី ៥៧,១នៃខែឧសភា នេះជាសន្ទស្សន៍មួយដែលមានកម្រិតខ្ពស់បំផុតចាប់តាំងពីឆ្នាំ២០០៦។ សន្ទស្សន៍ កម្រិតខ្ពស់នេះ អាចបញ្ជាក់ថាការស្ទុះងើបឡើងវិញនៃសេដ្ឋកិច្ចតំបន់អឺរ៉ុប កំពុងដំណើរការល្អ និងការបង្កើនសុទិដ្ឋិនិយមរបស់អតិថិជន

នៅពីក្រោយយុទ្ធនាការជំរុញវ៉ាក់សាំង។ សកម្មភាពនៅក្នុងឧស្សាហកម្ម សេវាកម្ម របស់អាឡឺម៉ង់បានកើនឡើងក្នុងខែមិថុនាក្នុងល្បឿនលឿនបំផុតចាប់តាំងពីខែមីនា ឆ្នាំ២០១១ ខណៈនៅប្រទេសបារាំងវិស័យនេះបានរីកដុះដាល បន្ទាប់ពីការបន្ធូរបន្ថយនៃការរឹតត្បិតពីជំងឺកូវីដ-១៩។

ទន្ទឹមនឹងនេះដែរ នៅចក្រភពអង់គ្លេស និងសហគមន៍អ៊ឺរ៉ុប ការធ្លាក់ចុះយ៉ាងខ្លាំងសម្រាប់ក្រុមហ៊ុនសេវាកម្មបានធូរស្រាលបន្តិចនៅខែមិថុនា ប៉ុន្តែសម្ពាធតម្លៃបានកើនឡើងខ្ពស់បំផុត៕ *ដោយ សេនចន្ទី*

*ប្រភព៖ Reuters.com ចេញផ្សាយថ្ងៃទី05ខែកក្កដាឆ្នាំ២០២១*

## អាមេរិក និងតៃវ៉ាន់ បន្តកិច្ចពិភាក្សាជំនួញជាថ្មី ក្រោយផ្អាករយៈពេល៥ឆ្នាំ



*ប្រភព ៖ ByTR110*

សហរដ្ឋអាមេរិក និងតៃវ៉ាន់ បានបន្តជាថ្មីនូវកិច្ចពិភាក្សាជំនួញ ក្រោយផ្អាករយៈពេល៥ឆ្នាំ។
ភាគីទាំងពីរបានពិភាក្សាគ្នាអំពី សិទ្ធិការងារ និងកម្មសិទ្ធិបញ្ញា និងបានព្រមព្រៀងគ្នា ប្រារព្ធធ្វើកិច្ចពិភាក្សា ជាប្រក្រតីថែមទៀត។ អ្នកតំណាងជំនួញនៃភាគីទាំងពីរ បានបង្ហាញនូវការគាំទ្រសម្រាប់ការងាររួមគ្នា ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងនូវសន្តិសុខ និងភាពធន់ នៃសង្វាក់ផ្គត់ផ្គង់ដ៏សំខាន់។ លោក John Feng ជាប្រធានមន្ត្រីចរចាជំនួញតៃវ៉ាន់ បានមានប្រសាសន៍ថា នេះជាការបោះជំហានដ៏សំខាន់មួយ ឆ្ពោះទៅរកការចុះហត្ថលេខាកិច្ចព្រមព្រៀងជំនួញទាំងស្រុង ជាមួយសហរដ្ឋអាមេរិក៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ដើមអំពិល ចេញផ្សាយថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី១២ ខែកក្កដា ឆ្នាំ២០២១

- កំណើននៃការបញ្ជាទិញគ្រឿងម៉ាស៊ីនសំខាន់ៗនៅក្នុងប្រទេសជប៉ុនដែលមិនរាប់បញ្ចូលកប៉ាល់ និងពីក្រុមហ៊ុនថាមពលអគ្គីសនី ក្នុងខែមេសា ឆ្នាំ ២០២១
- ការធ្លាក់ចុះតម្រូវការ លំនៅដ្ឋានសរុប នៅអូស្ត្រាលី ក្នុងខែឧសភាឆ្នាំ ២០២១
- កំណើនអត្រាអ្នកអត់ការងារធ្វើនៅក្នុងប្រទេសទួរគី ក្នុងខែមេសាឆ្នាំ ២០២១

ថ្ងៃអង្គារ៍ ទី១៣ ខែកក្កដា ឆ្នាំ២០២១

- ការធ្លាក់ចុះនៃការទិញ ប័ណ្ណរតនាគាររយៈពេល ១០ ឆ្នាំរបស់អាមេរិក
- អតិរេកពាណិជ្ជកម្មរបស់ចិន ក្នុងខែឧសភាឆ្នាំ ២០២១
- អត្រាអតិផរណាតម្លៃអ្នកប្រើប្រាស់នៅប្រទេសអាឡឺម៉ង់ត្រូវបានគេរំពឹងថានឹងធ្លាក់ចុះពី ២,៣ ភាគរយពីមួយឆ្នាំទៅមួយឆ្នាំ នៅក្នុងខែមិថុនា ឆ្នាំ ២០២១ ពីអត្រាខ្ពស់ជិត ១៣ ឆ្នាំដែលមាន

អត្រា ២,៥%កាលពីខែមុននិងស្របតាមការរំពឹងទុករបស់ទីផ្សារ។

ថ្ងៃពុធ ទី១៤ ខែកក្កដា ឆ្នាំ២០២១

- ឱនភាពថវិកាសហរដ្ឋអាមេរិក កាលពីខែឧសភា ឆ្នាំ ២០២១
- កំណើនការនាំចេញនៅកូរ៉េខាងត្បូង ក្នុងខែឧសភា ឆ្នាំ២០២១
- អត្រាគ្មានការងារធ្វើ នៅក្នុងប្រទេសកូរ៉េខាងត្បូងបានកើនឡើង នៅក្នុងខែឧសភាឆ្នាំ ២០២១

ថ្ងៃព្រហស្បតិ៍ ទី១៥ ខែកក្កដា ឆ្នាំ២០២១

- ការធ្លាក់ចុះ ការវិនិយោគភាគហ៊ុនដោយជនបរទេសនៅក្នុងប្រទេសជប៉ុន
- កំណើនការងារក្រៅម៉ោងនៅអូស្ត្រាលី នៅក្នុងខែឧសភា ឆ្នាំ ២០២១
- សេដ្ឋកិច្ចចិន បានកើនឡើងតាមការផ្លាស់ប្តូរតាមរដូវកាល ក្នុងត្រីមាសក្នុងរយៈពេលបីខែគិតត្រឹមខែមីនាឆ្នាំ ២០២១

ថ្ងៃសុក្រ ទី១៦ ខែកក្កដា ឆ្នាំ២០២១

- អត្រាអតិផរណានៅអាហ្សង់ទីនបានកើនឡើងដល់ ៤៨,៨០ ភាគរយនៅក្នុងខែឧសភាពី ៤៦,៣០ ភាគរយនៅក្នុងខែមេសាឆ្នាំ ២០២១
- ប្រទេសអ៊ីតាលីបានប្រកាសអតិរេកពាណិជ្ជកម្មចំនួន ៥,៨៧០ ពាន់លានអឺរ៉ូក្នុងខែមេសាឆ្នាំ ២០២១ បើប្រៀបធៀបនឹងឱនភាព ១,១១៧ ពាន់លានអឺរ៉ូនៅក្នុងខែដែលត្រូវគ្នានៃឆ្នាំមុន។
- អតិរេកពាណិជ្ជកម្ម របស់តំបន់ចាយប្រាក់អឺរ៉ូបានពង្រីកដល់ ១០,៩ ពាន់លានអឺរ៉ូនៅខែមេសា ឆ្នាំ ២០២១៕